# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ១០៥៦
ចុះថ្ងៃទី១៦-៥-២០១៩
សាលដីកា
លេខ៖ ១៦៩ក្រII«វ»
ចុះថ្ងៃទី ១៧-១២-២០២០

## គាថនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ៖ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៨ និងបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ភ្នំពេញ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ៖

សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សា
ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១០៥៦ ចុះថ្ងៃទី ១៦-៥-២០១៩ លើ៖

១ ជនជាប់ចោទឈ្មោះ [redacted] ម៉្រឹច ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិត្រពាំងខ្នារ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិត្រ[redacted]ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ[redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ទោសពីមុនគ្មាន ។ (ប្តឹងឧទ្ធរណ៍)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦២០ "អ" ជ.ឃ.ជ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ ។

-មានមេធាវី [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិ

២-ជនជាប់ចោទឈ្មោះ [redacted] សំបូរ ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិរមន់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូ[redacted]ខេត្តតាកែវ ឪពុកឈ្មោះ[redacted] "រស់" ម្តាយឈ្មោះ[redacted] "រស់" ប្រពន្ធឈ្មោះ [redacted] "រស់" មានកូន ០១នាក់ ទោសពីមុនគ្មាន ។(ប្តឹងឧទ្ធរណ៍)

ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៦១៩ "អ" ជ.ឃ.ជ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ ។

-មានមេធាវី [redacted] ម៉ាច ជាមេធាវីការពារសិទ្ធិ



Scanned with CamScanner

Scanned with CamScanner

<u>ជាប់ចោទពីបទ</u>៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រោយស្ពានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាបៃលធី សង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលមានបញ្ញត្តិ និងចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

<u>ឯរឿងហេតុមានដូចតទៅ៖</u>

កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង១៦ និង២០នាទី សមត្ថកិច្ចការិយាល័យប្រឆាំងគ្រឿងញៀនខុសច្បាប់នៃមន្ទីរប្រឆាំងគ្រឿងញៀន បានអនុវត្តវិធានញុះញង់ឲ្យលក់គ្រឿងញៀនខុសច្បាប់ នៅចំណុចក្រោយស្ពានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាបៃលធី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ មានឈ្មោ[redacted]ជ្រឹង ភេទប្រុស អាយុ៣២ឆ្នាំ និងឈ្មោះ: [redacted]សំបូរ ភេទប្រុស អាយុ៣៩ឆ្នាំ ឆែកឆេរឃើញក្រាមពណ៌សថ្លា ចំនួន ០១កញ្ចប់ (គេស្គាល់បឋមប្រភេទមេតំហ្វេតាមីន) ទម្ងន់ ១០,១១ក្រាម និងក្រាមពណ៌សថ្លាមួយកញ្ចប់ទៀត (គេស្គាល់បឋមប្រភេទមេតំហ្វេតាមីន) ទម្ងន់ ៨៧,៦១ ក្រាម ដាក់ក្នុងរ៉ាលីលើចង្កើម៉ូតូខាងមុខ ។ មុនពេលកើតហេតុ មានម៉ូយទំនាក់ទំនងទិញថ្នាំញៀនពីឈ្មោះ: [redacted] ជ្រឹង និងឈ្មោះ: [redacted] ភាស់។ បន្ទាប់មកឈ្មោះ: [redacted] ជ្រឹង បានទំនាក់ទំនងយកថ្នាំញៀនពីឈ្មោះ: [redacted] ភាស់ នៅចំណុចបន្ទប់ជួលរបស់ឈ្មោះ: រាមពេលទទួលថ្នាំញៀនរួចឈ្មោះ: [redacted] ជ្រឹង និងឈ្មោ[redacted]បូរ បានយកថ្នាំញៀនទៅប្រគល់ឲ្យម៉ូយ លុះពេលពួកគេកំពុងប្រគល់ថ្នាំញៀនឲ្យម៉ូយ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង រួចសមត្ថកិច្ចកសាងសំណុំរឿងរួមទាំងវត្ថុតាងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធី ។

**-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ÷ ៦២៦ "ក្រ២"ទ ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ÷**

១-ផ្តន្ទាទោស៖

ក-ឈ្មោះ: [redacted] ជ្រឹង ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិត្រពាំងខ្ពារ ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅភូមិត្រពាំង[redacted]ឪពុកឈ្មោ[redacted] "រ" ម្តាយឈ្មោះ: [redacted] "រ" ប្រពន្ធឈ្មោះ: [redacted]កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន ។

ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០(ដប់លាន)រៀល។

ខ-ឈ្មោះ: [redacted] សំបូរ ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើតនៅភូមិរមេន់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ទីលំនៅមុនពេលឃាត់ខ្លួន[redacted] ស្រុកសំរោង ខេត្តតាកែវ ឪពុកឈ្មោះ [redacted]



Scanned with CamScanner

Scanned with CamScanner

ម្ដាយឈ្មោះ [redacted] " រ" ប្រពន្ធឈ្មោះ រុណា លក្ខិណា "រ" មានកូន០២នាក់ ជានីតិជន ទោសពីមុនគ្មាន ។

ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០,០០០,០០០ (ដប់លាន) រៀល។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចក្រោយស្ពានីវ៉ៃប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ មុខសាលាប៉ែលពី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-រឹបអូសវត្ថុតាងមាន ថ្នាំញៀនប្រភេទម្សៅក្រាមសញ្ញា ទម្ងន់ទាំងអស់សរុប ៩៧,៧២ (កៅសិបប្រាំពីរ ក្បៀសចិតសិបពីរ) ក្រាម និងម៉ូតូម៉ាកហុងដាឌ្រីម ពណ៌ខ្មៅ ពាក់ស្លាក់លេខភ្នំពេញ ១HD-៨១៨៦ លេខតួ និងលេខម៉ាស៊ីន ND125M5309112 ចំនួន០១គ្រឿង។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ជ្រឹង និងឈ្មោះ [redacted] សំបូរ ។ ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៦៧៦ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សំបូរ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៖ ៦២៦"ក្រ២" ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៦៣៩ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៖ ៦២៦"ក្រ២" ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

-បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍នៃសាលាឧទ្ធរណ៍ភ្នំពេញ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០ ។

-បានឃើញ សេចក្តីសន្និដ្ឋានចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ។

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាជំនុំជម្រះសង្ខេបរបាយការណ៍រឿង

-ជនជាប់ចោទឈ្មោះ [redacted] សំបូរ (វត្តមាន) ។

-ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង (វត្តមាន) ។

-លោក [redacted] ម៉ាច មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន) ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង បានឆ្លើយថា ៖ ខ្លួនប្តឹងមកសាលាឧទ្ធរណ៍ ដោយសារ
តែសាលាដំបូងសម្រេចផ្តន្ទាទោសខ្លួនធ្ងន់ធ្ងរពេក ។ ថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន នៅ
មុខសាលាប៉ៃលធី ក្បែរស្ថានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ គឺខ្លួនបានពីឈ្មោះ [redacted]
ភាស់ យកទៅឲ្យឈ្មោះ ហេង ទិញក្នុងតម្លៃ ៣០០ដុល្លារអាមេរិក ដោយឈ្មោះ ភាស់ ឲ្យកម្រៃ
ខ្លួន ១០ម៉ឺនរៀល នៅមុនពេលឃាត់ខ្លួនៗមានមុខរបរជាកម្មករសំណង់ ។ ខ្លួនទើបតែប្រព្រឹត្ត
បានម្តងទេ ហើយខ្លួនស្គាល់ឈ្មោះ ហេង ដោយសារខ្លួនធ្លាប់ទិញគ្រឿងញៀនមកប្រើប្រាស់ ។
ថ្នាំញៀនដែលសមត្ថកិច្ចចាប់បាននោះ ឈ្មោះ [redacted] ភាស់ បានដាក់ចោលនៅបង្គោលភ្លើង ទល់
មុខសាលាប៉ៃលធី ដែលបានច្រកថង់ខ្មៅបិទជិត ដោយមានគេទូរស័ព្ទឲ្យយក ហើយឈ្មោះ
ហេង បានប្រើឲ្យខ្លួនទៅយក ។ ថ្នាំញៀនដែលឈ្មោះ [redacted] ភាស់ បានដាក់នៅបង្គោលភ្លើងនោះ
ខ្លួនពុំទាន់បានទៅយកទេ តែខ្លួនបានទៅយកលុយពីឈ្មោះ ហេង ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន
ព្រោះឈ្មោះ ហេង ជាសមត្ថកិច្ចដែលបង្កប់ ។ ខ្លួនត្រូវសមត្ថកិច្ចចាប់ខ្លួន នៅទល់មុខសាលា
ប៉ៃលធី ក្បែរស្ថានីយ៍ប្រេងសូគីមិចច្រមុះជ្រូកស្ទឹងមានជ័យ នៅម៉ោង ៥យប់ ហើយចាប់តែម្នាក់
ឯងទេ ។

-ជនជាប់ចោទឈ្មោះ [redacted] សំបូរ បានឆ្លើយថា ៖ ខ្លួនអង្គុយលើម៉ូតូ នៅមុនពេលសមត្ថ
កិច្ចចាប់ខ្លួន ពេលកំពុងតែនិយាយទូរស័ព្ទជាមួយប្អូនៗ នៅមុនពេលសមត្ថកិច្ចចាប់ខ្លួនៗបាន
ណាត់ជួបមិត្តស្រីខ្លួនដើរលេង ពុំមែនមកយកលុយដូចឈ្មោះ [redacted] ជ្រឹង នោះទេ ។ ខ្លួនជាជាង
ផ្សារដែកនៅតាមផ្ទះ ហើយឈ្មោះ [redacted] ជ្រឹង ជាជាងសំណង់ ពុំធ្លាប់ស្គាល់គ្នាទេ ។ ខ្លួន និង
ឈ្មោះ [redacted] ជ្រឹង ពុំមានទំនាក់ទំនងគ្នាទេ ស្នាក់នៅខុសគ្នា និងចាប់ខ្លួននៅពេលវេលាខុស
គ្នា។ ចំពោះគ្រឿងញៀន ដកហូតបាន គឺនៅលើម៉ូតូ តែឆែកឆេរ ពុំឃើញមានគ្រឿងញៀន នៅ
លើម៉ូតូ និងក្នុងកាតាបទេ តែសមត្ថកិច្ចបានឆែករកឃើញនៅក្នុងកាតាបដាក់នៅលើទូកម៉ូតូ
ដែលឈ្មោះ រាម បានផ្ញើទៅឲ្យគេ ហើយខ្លួនមិនដឹងមានអ្វីនៅក្នុងនោះទេ និងមិនដឹងថា ជាថ្នាំ
ញៀន ។ សមត្ថកិច្ចចាប់ខ្លួននៅម៉ោងប្រហែល ៥ ទៅ ៦ ល្ងាច ហើយសមត្ថកិច្ចបានចាប់យក
វត្ថុតាង និងម៉ូតូ ទៅប៉ុស្តិ៍តែម្តង ។

<u>តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន</u>

នៅក្នុងសំណុំរឿងនេះ អង្គហេតុនៃការឃាត់ខ្លួនជនជាប់ចោទខាងលើនេះ តំណាងមហា
អយ្យការ យល់ឃើញថា ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសព្រហ្មទណ្ឌ របស់ជនជាប់
ចោទ ធ្វើទៅតាមអំពើដែលបានប្រព្រឹត្តរបស់ខ្លួន ដោយយោងតាមគោលការណ៍ឯកត្តកម្មនៃការ
ទទួលខុសត្រូវព្រហ្មទណ្ឌ ហើយវត្ថុតាងមានចំនួន ២កញ្ចប់ខុសគ្នា និងទីកន្លែងខុសគ្នា ។ ដូច្នេះ
តំណាងមហាអយ្យការ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ ពិចារណា និងសម្រេចតម្កល់ការចោទប្រកាន់
ទុកជាបានការ ។

<u>មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន</u>

លោក [redacted] ភិច ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយ
ពីបានកិច្ចពិភាក្សាដេញដោលរួចមក ឃើញថា កូនក្តីខ្លួនទាំងពីរនាក់នេះ សាលាដំបូងរាជធានី

ភ្នំពេញ ចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន សម្រេចដាក់ពន្ធនាគារកំណត់ ៨ឆ្នាំ ដូចគ្នា ប៉ុន្តែបើពិនិត្យទៅលើអង្គហេតុ និងការសួរដេញដោលឃើញថា ការឃាត់ខ្លួនកូនក្តីរបស់ខ្លួនទាំងពីរនាក់នេះ គឺនៅទីកន្លែងផ្សេងគ្នា ពេលវេលាខុសគ្នា ហើយការដកហូតនូវសារធាតុញៀនក៏ផ្សេងគ្នាដែរ ដូចទៅនឹងតំណាងមហាអយ្យការលើកឡើង ពីគោលការណ៍ឯកត្តកម្មនៃទោស ដែលត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។ បើយើងពិនិត្យលើសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចមកនេះឃើញថា ការសម្រេចដាក់ពន្ធនាគារកំណត់ ៨ឆ្នាំដូចគ្នានោះ ពុំត្រឹមត្រូវនោះតាមទម្រង់ច្បាប់ទេ ដោយហេតុថា បរិមាណធាតុសុទ្ធគ្រឿងញៀនរបស់ឈ្មោះ [redacted]សំបូរ នោះ លទ្ធផលកោសល្យវិច័យ ៦៣,៩១ក្រាម ដោយផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ រីឯបរិមាណគ្រឿងញៀនដែលសមត្ថកិច្ចចាប់យករបស់ឈ្មោះ [redacted] ជ្រឹង នោះ មានបរិមាណធាតុសុទ្ធ ៧,៦៣ក្រាម ដោយសរសេរអាងតែមាត្រា ៤០ តែពុំបានដាក់ចំណុចណាដូចការលើកឡើងដូចឈ្មោះ [redacted]សំបូរ នោះទេ ដែលជាលើកសំអាងហេតុដោយបន្លំ ។ ដូច្នេះ ការលើកឡើងរបស់សាលាដំបូង និងការសម្រេចផ្តន្ទាទោសលើកូនក្តីរបស់ខ្លួនខុសនឹងទម្រង់ច្បាប់ ។ ដូច្នេះ តាងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted]ជ្រឹង និងឈ្មោះ[redacted] សំបូរ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិចារណា និងសម្រេចផ្តន្ទាទោសដោយញែកចេញពីគ្នា តាមតារាង តាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសម្រេចតាមច្បាប់ ។

## សំណូមពរជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted]សំបូរ បានសំណូមពរថាៈសុំជួយរកយុត្តិធម៌ឲ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ជ្រឹង បានសំណូមពរថាៈសុំជួយបន្ធូរបន្ថយទោសឲ្យខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ក្រោយពីបានស្តាប់សំណូមពររបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា÷

១/.បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ[redacted] សំបូរ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៖ ៦២៦"ក្រ២"វ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងមាត្រា៩៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ភ្នំពេញទទួលជំនុំជម្រះបាន ។



Scanned with CamScanner

២/.បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted]
ជ្រឹង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ៖ ៦២៦"ក្រ២"៧ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩
របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងត្រឹមត្រូវ
តាមកំណត់ច្បាប់ យោងមាត្រា៨៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៣៧៥
នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ
ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ភ្នំពេញ ទទួលជំនុំជម្រះបាន ។

៣/.តាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោលឃើញថា ៖ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ
២០១៩ សមត្ថកិច្ចការិយាល័យប្រឆាំងគ្រឿងញៀននៃមន្ទីរប្រឆាំងគ្រឿងញៀន បានអនុវត្ត
វិធានញុះញង់ឲ្យលក់គ្រឿងញៀនខុសច្បាប់ បានចុះបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវ
សារធាតុញៀន ធ្វើការឃាត់ខ្លួនបានចំនួនពីនាក់ ជនជាប់ចោទឈ្មោះ [redacted] សំបូរ ក្នុងបទ
ល្មើសជាក់ស្តែង ដោយដកហូតបាននូវវត្ថុតាងដែលជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន (ម៉ា
ទឹកកក) មានទម្ងន់សរុប ៨៧,៦១ក្រាម ដែលមានបរិមាណធាតុសុទ្ធសរុប$\frac{\text{៨៧,៦១ក្រាម×៧២.៩៥\%}}{\text{១០០}}$ =
៦៣,៩១ ក្រាម និងជនជាប់ចោទឈ្មោះ [redacted] ជ្រឹង ដោយដកហូតបាននូវវត្ថុតាងដែលជាគ្រឿង
ញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) មានទម្ងន់សរុប ១០,១១ក្រាម ដែលមានបរិមាណ
ធាតុសុទ្ធសរុប$\frac{\text{១០,១១ក្រាម×៧៥.៨៣\%}}{\text{១០០}}$ = ៧,៦៣ ក្រាម ប្រាកដមែន ដែលជាទម្រង់មួយនៃអំពើមាន
ធាតុផ្សំ និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សំបូរ និងឈ្មោះ [redacted]
ជ្រឹង ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការ
ត្រួតពិនិត្យគ្រឿងញៀន ដូចមានខ្លឹមសារក្នុងផ្នែកសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌ របស់
សាលាដំបូងរាជធានីភ្នំពេញបានបញ្ជាក់ស្រាប់ ហើយក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍
ភ្នំពេញ ឯកភាព នឹងសំអាងហេតុទាំងនេះ ដោយមិនចាំបាច់លើកយកសំអាងហេតុដដែលនេះ
មកបញ្ជាក់ជាថ្មីទៀតទេ។

៤/.តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ នៅក្នុងសំណុំរឿងនេះ អង្គហេតុ
នៃការឃាត់ខ្លួនជនជាប់ចោទខាងលើនេះ តំណាងមហាអយ្យការ យល់ឃើញថា ការទទួល
ខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសព្រហ្មទណ្ឌ របស់ជនជាប់ចោទ ធ្វើទៅតាមអំពើរបស់ខ្លួន
ដែលបានប្រព្រឹត្តរបស់ខ្លួន ដោយយោងតាមគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្ម
ទណ្ឌ ហើយវត្ថុតាងមានចំនួន ២កញ្ចប់ខុសគ្នា និងទីកន្លែងខុសគ្នា។ ដូច្នេះ តំណាងមហា
អយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ ពិចារណា និងសម្រេចតម្កល់ការចោទប្រកាន់ទុកជាបាន
ការ ។

ឃើញថា សេចក្តីសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវ គប្បីពិចារណា និងសម្រេច ។

៥/.ការដែលជនជាប់ចោទឈ្មោះ [redacted] សំបូរ ក៏ដូចជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
ប្តឹងសុំឲ្យជួយបន្ធូរបន្ថយទោសនោះ ឃើញថា ពុំមានលក្ខណៈត្រឹមត្រូវតាមច្បាប់ឡើយ ព្រោះ
បរិមាណធាតុសុទ្ធនៃគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ដែលដកហូតបានពីជនជាប់ចោទ
មានចំនួន ៦៣,៩១ ក្រាម (ហុកសិបបីកណ្តក់សញ្ញាកៅសិបមួយ)ក្រាម ត្រូវផ្តន្ទាទោសដាក់
ពន្ធនាគារកំណត់ពី ០៥ឆ្នាំ ទៅ ១០ឆ្នាំ និងពិន័យជាប្រាក់ពី ១០.០០០.០០០រៀល ទៅ
២០.០០០.០០០រៀល ។ ដូចនេះ ការប្រកាសទោសរបស់សាលាដំបូងលើជនជាប់ចោទឈ្មោះ
[redacted] សំបូរ ស្ថិតនៅក្នុងបញ្ញត្តិច្បាប់ហើយ ។



Scanned with CamScanner

Scanned with CamScanner